បេឡាជាតិសន្តិសុខសង្គម

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែ

លេខ៖៦

## មាតិកា

### ព្រឹត្តិការណ៍សំខាន់ៗ

➤ ព្រឹត្តិការណ៍សំខាន់ៗ......................................................២

### ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន

➤ ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស............២២

### ខិត្តប័ណ្ណផ្សព្វផ្សាយ

➤ ខិត្តប័ណ្ណផ្សព្វផ្សាយ របស់បេឡាជាតិសន្តិសុខសង្គមទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស. ..................២៤

ទាញយកប្រើប្រាស់ឥឡូវនេះ!!
NSSF Member App

Google Play
App Store




## រចនាសម្ព័ន្ធព្រឹត្តិបត្រ ខែវិច្ឆិកា ឆ្នាំ២០២៥

**ឯកឧត្តម ម៉េង ហុង**
**អគ្គនាយក ប.ស.ស.**

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តមបណ្ឌិត **ហេង សុផាន់ណារិទ្ធ** |
| **និពន្ធនាយក** | លោក **អ៊ុក សំអូន** |
| **និពន្ធនាយករង** | លោកស្រី **ចាន់ ស៊ីណុន** |
| | លោក **ឃុន វិចិត្រ** |
| **លេខានិពន្ធ** | លោក **យន គន្ធា** |
| | លោក **យង់ សុខន** |
| **ផ្នែកការីកុំព្យូទ័រ** | លោក **អ៊ុង ស៊ីខឿ** |
| | អ្នកស្រី **ទិត បញ្ញា** |


សូមអានបន្តនៅទំព័រទី២

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅបាត់ដំបង បានផ្តល់ឱកាសការងាររាប់ម៉ឺនកន្លែងដល់អតីតពលករមកពីប្រទេសថៃ

## កម្រងរូបភាពសកម្មភាព












នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) និងទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា និងរដ្ឋបាលខេត្តបាត់ដំបង បានរៀបចំ "ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ" នៅខេត្តបាត់ដំបង។

ក្នុងកម្មវិធីនេះដែរ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីក្នុងពិធីបើកពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ ដោយនាំយកឱកាសការងារប្រមាណជាង ១,១ម៉ឺនកន្លែង និងព័ត៌មានស្តីពីអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម ក៏ដូចជាព័ត៌មានស្តីអំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដោយឥតគិតថ្លៃផងដែរ។

ថ្លែងក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានលើកឡើងថា ការធ្វើការងារនៅក្នុងស្រុកមានភាពល្អប្រសើរជាងការធ្វើការនៅប្រទេសថៃ ដូចជាការទទួលបានអត្ថប្រយោជន៍ ប.ស.ស. ដែលរួមមាន ការព្យាបាលជំងឺដោយឥតគិតថ្លៃពេលឈឺ ឬពេលមានគ្រោះថ្នាក់ ទទួលបានប្រាក់សោធន អាចរស់នៅជួបជុំក្រុមគ្រួសារ អាចចូលរួមពិធីបុណ្យប្រពៃណីជាតិនានា ក៏ដូចជាពិធីជួបជុំនានាផងដែរ ហើយម្យ៉ាងទៀតដោយសារយើងជាខ្មែរដូចគ្នា គឺមានភាពងាយស្រួលក្នុងការទំនាក់ទំនង និងយោគយល់គ្នា ជាពិសេសនៅកន្លែងធ្វើការតែម្តង។ សូមបញ្ជាក់ថា កម្មវិធីពិពណ៌ខាងលើប្រព្រឹត្តទៅចំនួន២ថ្ងៃ គឺនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ធ្វើនៅវត្តថ្មគោល ជិតរង្វង់មូលថ្មគោល ស្រុកថ្មគោល និងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ធ្វើនៅទីធ្លាសាធារណៈ ឃុំគារ ស្រុកមោងឬស្សី ខេត្តបាត់ដំបង។

ដូច្នេះសម្រាប់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសបងប្អូនពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដែលកំពុងស្វែងរកការងារធ្វើ ឬចង់ផ្លាស់ប្តូរការងារ គឺអាចធ្វើការប្រឹក្សាយោបល់បានភ្លាមៗ ឬក៏អាចសាកសួរព័ត៌មានបន្ថែមតាមរយៈលេខទូរសព្ទ Hotline ១២៩៧។ ដោយឡែកសម្រាប់ចម្ងល់ផ្សេងៗពាក់ព័ន្ធជាមួយនឹងអត្ថប្រយោជន៍របបសន្តិសុខសង្គម បងប្អូនអាចទំនាក់ទំនងតាមរយៈលេខទូរសព្ទ Hotline ១២៨៦ ឬតាមបណ្តាញសង្គមផ្លូវការរបស់ ប.ស.ស.។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់ការចុះបញ្ជីមន្ត្រីសាធារណៈ មកក្នុង ប.ស.ស. ដើម្បីពិនិត្យ ពិភាក្សាបច្ចេកទេសក្នុងការផ្ដល់អត្ថប្រយោជន៍របបសន្តិសុខសង្គមដល់ក្រុមគោលដៅ ស្របតាមលិខិតបទដ្ឋានថ្មី។

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់ការចុះបញ្ជីមន្ត្រីសាធារណៈមកក្នុង ប.ស.ស. បានដឹកនាំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់ការចុះបញ្ជីមន្ត្រីសាធារណៈ មកក្នុង ប.ស.ស. ដែលមានសមាជិកចូលរួមមកពីតំណាងក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងមូលនិធិជាតិជំនួយសង្គម ពិភាក្សាលើការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន និងនីតិវិធីនៃការប្រកាសបង់ភាគទានសម្រាប់មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

ក្នុងឱកាសដឹកនាំកិច្ចប្រជុំនេះ **ឯកឧត្តម ម៉េង ហុង** បានថ្លែងនូវមតិស្វាគមន៍ និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចប្រជុំនេះ ដែលជាជំហានមួយដ៏សំខាន់ក្នុងការលើកកម្ពស់គុណភាពទិន្នន័យបច្ចុប្បន្នរបស់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ក៏ដូចជានីតិវិធីនៃការប្រកាសបង់ភាគទានសម្រាប់មន្ត្រីដែលផ្អែកលើកិច្ចព្រមព្រៀងការងារ និងក្រុមគោលដៅពាក់ព័ន្ធផ្សេងៗទៀត ដែលត្រូវទទួលបានការធានាដោយរបបសន្តិសុខសង្គមបានទាន់ពេលវេលា ប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

តាមរយៈកិច្ចប្រជុំពេញមួយព្រឹកនេះ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធបានផ្តល់ធាតុចូល ពិភាក្សាយ៉ាងលម្អិត ស៊ីជម្រៅ និងបានដោះស្រាយបញ្ហាប្រឈមមួយចំនួនប្រកបដោយផ្លែផ្កា ដែលជួយសម្រួលដល់ការអនុវត្តការងារបច្ចុប្បន្នរបស់ ប.ស.ស. កាន់តែមានភាពងាយស្រួល និងឆាប់រហ័សជាងមុន និងអាចធានាបានដល់ការអនុវត្តរបបសន្តិសុខសង្គម ព្រមទាំងការផ្តល់អត្ថប្រយោជន៍នានាជូនដល់ក្រុមគោលដៅ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងទាន់ពេលវេលា៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម ម៉េង ហុង អញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុង ប.ស.ស. ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុងប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីបូកសរុបលទ្ធផលការងារសម្រេចបាន និងដាក់ចេញនូវយន្តការដោះស្រាយបញ្ហាប្រឈមសំខាន់ៗ ដែលនៅសេសសល់ ក៏ដូចជាលើកទិសដៅសម្រាប់អនុវត្តការងារបន្ត។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ក៏បានជំរុញដល់ថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទ ត្រូវបង្កើនកិច្ចសហការរវាងគ្នា ដោយមានភាពយោគយល់អធ្យាស្រ័យគ្នា ពិសេសត្រូវមានសាមគ្គីភាពផ្ទៃក្នុងជាធ្លុងមួយ ដើម្បីសម្រេចឱ្យបាននូវបេសកកម្មស្នូលរបស់ ប.ស.ស. ក្នុងការគ្រប់គ្រង និងផ្តល់អត្ថប្រយោជន៍ជូនសមាជិក ប.ស.ស. ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងប្រព័ន្ធគាំពារសង្គមមួយប្រកបដោយសមធម៌ និងចីរភាព។

សូមបញ្ជាក់ថា កិច្ចប្រជុំផ្ទៃក្នុងនាព្រឹកនេះ ប្រព្រឹត្តទៅនៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមដោយផ្ទាល់ពីសំណាក់ឯកឧត្តមអគ្គនាយករង លោក/លោកស្រីប្រធាននាយកដ្ឋាន/អង្គភាព លោក/លោកស្រីអនុប្រធាននាយកដ្ឋាន និងចូលរួមតាមប្រព័ន្ធ Zoom ពីសំណាក់លោក/លោកស្រីប្រធាន និងអនុប្រធានសាខា ប.ស.ស. ខេត្ត-ខណ្ឌ សរុបចំនួន២៤៨រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# គណៈប្រតិភូ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញចូលរួមសិក្ខាសាលាចែករំលែកឧត្តមានុវត្តន៍ ក្រោមប្រធានបទស្តីពី វឌ្ឍនភាពរួម៖ កំណែទម្រង់បរិវត្តកម្មដើម្បីធានាអនាគតសម្រាប់ទាំងអស់គ្នា របស់សមាគមសន្តិសុខសង្គមអាស៊ាន (ASSA) លើកទី៤២ នៅប្រទេសព្រុយណេ

## កម្រងរូបភាពសកម្មភាព



















នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំគណៈប្រតិភូ ប.ស.ស. ចូលរួមសិក្ខាសាលាចែករំលែកឧត្តមានុវត្តន៍ ក្រោមប្រធានបទស្តីពី វឌ្ឍនភាពរួម៖ កំណែទម្រង់បរិវត្តកម្មដើម្បីធានាអនាគតសម្រាប់ទាំងអស់គ្នា របស់សមាគមសន្តិសុខសង្គមអាស៊ាន (ASSA) លើកទី៤២ នៅទីក្រុងបានដាសេរីបេហ្គាវ៉ាន់ នៃប្រទេសព្រុយណេ។

ក្នុងឱកាសនោះផងដែរ មន្ត្រីជំនាញ ប.ស.ស. ក៏បានចូលរួមធ្វើបទបង្ហាញស្តីពី បរិវត្តកម្មឌីជីថលសម្រាប់ប្រព័ន្ធប្រតិបត្តិការ ប.ស.ស. និងបានចែករំលែកឧត្តមានុវត្តន៍ពាក់ព័ន្ធទៅនឹងវឌ្ឍនភាព នៃការអនុវត្តរបបសន្តិសុខសង្គម ព្រមទាំងការអភិវឌ្ឍប្រព័ន្ធឌីជីថល ប.ស.ស. កម្ពុជា។

សិក្ខាសាលាចែករំលែកឧត្តមានុវត្តន៍ខាងលើ រៀបចំដោយមូលនិធិសោធនិវត្តន៍សម្រាប់កម្មករនិយោជិត (ETF) នៃប្រទេសព្រុយណេ ដោយមានការចូលរួមពីតំណាងអង្គការអន្តរជាតិ និងតំណាងស្ថាប័នសន្តិសុខសង្គមជាសមាជិកនៃសមាគម ASSA ចំនួន ២០ស្ថាប័ន ដែលមកពីបណ្តាប្រទេសអាស៊ានទាំង ១០ សរុបចំនួនប្រមាណជាង ១០០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បើកពិធីផ្សព្វផ្សាយស្តីពី ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ ជូនដល់មន្ត្រីទទួលបន្ទុកការងារ ប.ស.ស. ប្រចាំក្រសួង ស្ថាប័ន និងអង្គភាព

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតី បើកពិធីផ្សព្វផ្សាយស្តីពី "ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ ជូនដល់មន្ត្រីទទួលបន្ទុកការងារ ប.ស.ស. ប្រចាំក្រសួង ស្ថាប័ន និងអង្គភាព" សរុបជាង ២០០រូប នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានគូសបញ្ជាក់ថា ប្រព័ន្ធគាំពារសង្គម បាននិងកំពុងបោះជំហានទៅមុខប្រកបដោយវឌ្ឍនភាព ស្របតាមកម្មវិធីគោលនយោបាយអាទិភាព និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០២៤-២០៣៥ គឺជាផែនទីបង្ហាញផ្លូវរយៈពេលវែង ដែលផ្តោតលើសសរស្តម្ភចំនួន២ គឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ក្នុងនោះប្រព័ន្ធសន្តិសុខសង្គម ដែលមានបេឡាជាតិសន្តិសុខសង្គម ដែលហៅជាអក្សរកាត់ថា ប.ស.ស. ជាស្ថាប័នប្រតិបត្តិករតែមួយគត់ ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងផ្នែកនិកម្មភាពការងារ ដែលជួយដល់សមាជិកក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗ នៃប្រាក់ចំណូលដោយសារការឈឺថ្កាត់ មាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ពិការភាព ចូលនិវត្តន៍ និងមរណភាពនៃអ្នកដែលរកចំណូលសម្រាប់គ្រួសារ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានលើកឡើងបន្តទៀតថា ពិធីផ្សព្វផ្សាយនាពេលនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីឱ្យមន្ត្រីទទួលបន្ទុកការងារ ប.ស.ស. ប្រចាំក្រសួង ស្ថាប័ន និងអង្គភាព បានឈ្វេងយល់បន្ថែមឱ្យកាន់តែច្បាស់អំពីនីតិវិធីចុះបញ្ជិកា និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ព្រមទាំងជាមូលដ្ឋានក្នុងការយកទៅអនុវត្ត ឱ្យកាន់តែទូលំទូលាយជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួនផងដែរ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា មន្ត្រីទទួលបន្ទុកការងារ ប.ស.ស. ប្រចាំក្រសួង ស្ថាប័ន និងអង្គភាព នឹងសហការជួយផ្សព្វផ្សាយបន្តអំពីអត្ថប្រយោជន៍របបសន្តិសុខសង្គម ស្របតាមបទប្បញ្ញត្តិជាធរមាន នៅតាមក្រសួង ស្ថាប័ន និងអង្គភាពរៀងៗខ្លួន៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បើកវគ្គបណ្តុះបណ្តាលស្តីពី "ពិធីការ និងបដិសណ្ឋារកិច្ច" និង "ការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន" ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិករបស់ខ្លួន

## កម្រងរូបភាពសកម្មភាព







នាព្រឹកថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកវគ្គបណ្តុះបណ្តាលស្តីពី "ពិធីការ និងបដិសណ្ឋារកិច្ច" និង "ការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន" ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិករបស់ខ្លួន ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលប្រព្រឹត្តិទៅដោយផ្ទាល់នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

ក្នុងឱកាសអញ្ជើញបើកវគ្គបណ្តុះបណ្តាលខាងលើ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានបញ្ជាក់ឱ្យដឹងថា ការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលខាងលើនេះ គឺដើម្បីបង្កើនចំណេះដឹង ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក ក្នុងការទទួលបដិសណ្ឋារកិច្ចភ្ញៀវថ្នាក់ជាតិ និងអន្តរជាតិ ការរៀបចំកិច្ចប្រជុំ ការរៀបចំសិក្ខាសាលា និងព្រឹត្តិការណ៍ផ្សេងៗ ក៏ដូចជាជំនាញបច្ចេកទេសក្នុងការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន ដែលជាមូលដ្ឋានគ្រឹះមួយដ៏មានសារៈសំខាន់សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់ ទាំងនៅស្នាក់ការកណ្តាល និងសាខា ប.ស.ស. ខេត្ត-ខណ្ឌ ក្នុងយុគសម័យឌីជីថល ដើម្បីរៀបចំឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត ប្រកបដោយកេរ្តិ៍ឈ្មោះ និងកិត្តិយសជូនអង្គភាពរបស់ខ្លួន។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមទាំងអស់ដែលបានចូលរួម នឹងចូលរួមយ៉ាងសកម្មក្នុងការត្រង់ត្រាប់ស្តាប់ និងសួរសំណួរឱ្យបានផុសផុល ទៅកាន់លោកគ្រូឧទ្ទេស ដើម្បីឱ្យគ្រូឧទ្ទេសធ្វើការបកស្រាយ និងពន្យល់ឱ្យបានកាន់តែយល់ច្បាស់ជូន និងត្រូវយកចំណេះ ជំនាញ និងបទពិសោធន៍នេះ ទៅប្រើប្រាស់ក្នុងការរៀបចំកម្មវិធីបដិសណ្ឋារកិច្ចឱ្យកាន់តែមានភាពល្អប្រសើរ។

សូមបញ្ជាក់ថា៖ វគ្គបណ្តុះបណ្តាលខាងលើនេះ ប្រព្រឹត្តទៅចំនួន ៣ថ្ងៃពេញ គឺចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អគ្គនាយករង ប.ស.ស. អញ្ជើញជាអធិបតីបិទវគ្គបណ្តុះបណ្តាល ស្តីពី "ពិធីការ បដិសណ្ឋារកិច្ច ការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន"

## កម្រងរូបភាពសកម្មភាព



នារសៀលថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីបិទវគ្គបណ្តុះបណ្តាលស្តីពី "ពិធីការ បដិសណ្ឋារកិច្ច ការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន" ដោយមានការចូលរួមពីសិក្ខាកាមសរុបប្រមាណ ៩០រូប ដែលជាថ្នាក់ដឹកនាំមន្ត្រីរាជការ និងបុគ្គលិករបស់ ប.ស.ស. មកពីសាខាខេត្ត នាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ នៅទីស្នាក់ការកណ្តាល ប.ស.ស.។

ក្នុងឱកាសបិទវគ្គបណ្តុះបណ្តាល **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានថ្លែងអំណរគុណចំពោះការចែករំលែកចំណេះដឹង បទពិសោធន៍របស់គ្រូឧទ្ទេស ដែលបានបណ្តុះបណ្តាលផ្នែកពិធីការ បដិសណ្ឋារកិច្ច ការប្រើប្រាស់ប្រព័ន្ធធនធានមនុស្ស និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានជាផ្នែកដ៏សំខាន់ក្នុងការជួយលើកកម្ពស់កិត្តិយសរបស់ស្ថាប័នក្នុងការទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ និងសម្រាប់ជំរុញប្រសិទ្ធភាពការងាររបស់ស្ថាប័ន ព្រមទាំងការការពារប្រព័ន្ធរបស់ ប.ស.ស. ឱ្យមានភាពរឹងមាំដើម្បីឆ្លើយតបទៅនឹងយុគសម័យឌីជីថលនាពេលបច្ចុប្បន្ននេះផងដែរ។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា តាមរយៈការឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១២-១៤ ខែវិច្ឆិកា ឆ្នាំ២០២៥នេះ សិក្ខាកាមទាំងអស់នឹងយកចំណេះដឹង បទពិសោធន៍ដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះ ទៅអនុវត្តការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ដល់ការងារពិធីការ និងការផ្តល់សេវាសាធារណៈរបស់ ប.ស.ស. កាន់តែរីកចម្រើនថែមទៀត៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ ដឹកនាំអង្គភាពក្រោមឱវាទ ប.ស.ស. ជួបពិភាក្សាជាមួយប្រតិភូនិយ័តករសន្តិសុខសង្គមដើម្បីផ្តល់កិច្ចសហការក្នុងការត្រួតពិនិត្យលើដំណើការ នៃការអនុវត្តការងាររបស់ ប.ស.ស.

## កម្រងរូបភាពសកម្មភាព







នារសៀលថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. បានដឹកនាំនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ប.ស.ស. ចូលរួមជួបប្រជុំពិភាក្សាជាមួយប្រតិភូនិយ័តករសន្តិសុខសង្គម ដឹកនាំដោយ **លោកស្រី ថន កេណ្ណារ័ត្ន** អគ្គនាយករង នៃនិយ័តករសន្តិសុខសង្គម និងជាប្រធានប្រតិភូ ដើម្បីផ្តល់កិច្ចសហការក្នុងការត្រួតពិនិត្យការអនុវត្តការងារជាក់ស្តែងរបស់ ប.ស.ស. ស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

មានប្រសាសន៍ស្វាគមន៍ប្រតិភូ នៃនិយ័តករសន្តិសុខសង្គម **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ប្រតិភូនិយ័តករសន្តិសុខសង្គម ដែលបានចុះមកត្រួតពិនិត្យលើការអនុវត្តការងាររបស់ ប.ស.ស. ក្នុងឱកាសនោះដែរ **ឯកឧត្តមបណ្ឌិត** ក៏បានចង្អុលបង្ហាញដល់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទ ប.ស.ស. ត្រូវផ្តល់កិច្ចសហការពេញលេញក្នុងការផ្តល់ទិន្នន័យ ឯកសារ និងព័ត៌មានចាំបាច់នានា ដើម្បីសម្រួលដល់ដំណើរការត្រួតពិនិត្យរបស់និយ័តករសន្តិសុខសង្គម ប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កាខ្ពស់។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានបន្ថែមថា ការចុះមកត្រួតពិនិត្យនេះ ជាយន្តការពង្រឹងប្រតិបត្តិការជាក់ស្តែងរបស់អង្គភាពប្រតិបត្តិករ ប.ស.ស. ក្នុងការធានាឱ្យដំណើរការ និងការអនុវត្តរបបសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព ប្រសិទ្ធភាព ស្របតាមច្បាប់ជាធរមាន ព្រមទាំងអាចជួយកែសម្រួលនូវចំណុចខ្វះខាត និងធានាផលប្រយោជន៍រួមរបស់សមាជិក ប.ស.ស.។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** សង្ឃឹមថា អង្គភាពទាំងពីរ នឹងចូលរួមកិច្ចសហប្រតិបត្តិការដ៏ល្អនេះ ប្រកបដោយភាពរលូន និងផ្លែផ្កា ដើម្បីជំរុញឱ្យការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជាកាន់តែមានភាពរឹងមាំ ប្រកបដោយគណនេយ្យភាព និងគុណភាពនៃការផ្តល់សេវាសន្តិសុខសង្គមជូនដល់សមាជិក ប.ស.ស. ព្រមទាំងផ្តល់ទំនុកចិត្តខ្ពស់ដល់សាធារណជនផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បន្តផ្សព្វផ្សាយអំពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដល់សិស្សនាយនគរបាល និងនាយនគរបាលរងជំនាន់ទី១៩ លើកទី២ នៅខេត្តសៀមរាប

## កម្រងរូបភាពសកម្មភាព













នៅព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **លោកឧត្តមសេនីយ៍ទោ បណ្ឌិត សាយ រិទ្ធីសក្តិ** នាយកសាលានគរបាលជាតិភូមិភាគ៤ បានអញ្ជើញជាសហាធិបតីបើកពិធីផ្សព្វផ្សាយ ស្តីពី ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ជូនដល់សិស្សនាយនគរបាល និងនាយនគរបាលរងជំនាន់ទី១៩ លើកទី២ ដែលបានប្រព្រឹត្តទៅនៅសាលានគរបាលជាតិភូមិភាគ៤ ស្ថិតក្នុងទឹកដីខេត្តសៀមរាប ដោយមានអ្នកចូលរួមសរុបចំនួន ១៨៦រូប។

នៅក្នុងពិធីផ្សព្វផ្សាយ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានបញ្ជាក់ថា ការផ្តល់ការថែទាំសុខភាពដល់សិស្សនាយនគរបាល និងនាយនគរបាលរង គឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតពីប្រមុខរាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់សិស្សនាយនគរបាល និងនាយនគរបាលរង នៅពេលមានបញ្ហាសុខភាព មាតុភាព ឬមានគ្រោះថ្នាក់ផ្សេងៗ ជាយថាហេតុក្នុងអំឡុងពេលកំពុងសិក្សា និងទទួលបានសេវាពិនិត្យ ព្យាបាលដោយឥតគិតថ្លៃតាមរយៈ ប.ស.ស. ។

ក្នុងឱកាសជាមួយគ្នា **លោកឧត្តមសេនីយ៍ទោ បណ្ឌិត សាយ រិទ្ធីសក្តិ** នាយកសាលានគរបាលជាតិភូមិភាគ៤ បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និង ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានយ៉ាងសកម្ម និងរៀបចំបទបង្ហាញយ៉ាងលម្អិត និងមានសារៈសំខាន់ ដើម្បីឱ្យថ្នាក់ដឹកនាំ និងសិស្សនាយនគរបាល និងនាយនគរបាលរង នៅសាលានគរបាលជាតិភូមិភាគ៤ បានយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍ និងសិទ្ធិដែលត្រូវទទួលបានពី ប.ស.ស.។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បន្តរៀបចំសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូល លើយុទ្ធសាស្ត្រពង្រីកកិច្ចគាំពារសង្គមដល់ប្រជាជនជនបទបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ

## កម្រងរូបភាពសកម្មភាព













នាព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ តំណាងអង្គការហ្គ្រេត (GRET) ជំនាញការនៃអង្គការហ្គ្រេត (GRET) ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) និងដៃគូពាក់ព័ន្ធ សរុបចំនួនប្រមាណ ៦០រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី "យុទ្ធសាស្ត្រពង្រីកកិច្ចគាំពារសង្គមដល់ប្រជាជនជនបទបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ" ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាប្រធានគណៈកម្មការសម្របសម្រួលគម្រោង SASI នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

សិក្ខាសាលាខាងលើ ត្រូវបានរៀបចំឡើងក្រោមក្របខ័ណ្ឌនៃគម្រោង SASI ក្នុងគោលបំណងដើម្បីប្រមូលធាតុចូល និងពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងស្វែងរកចំណុចរួមក្នុងការឆ្ពោះទៅរកការឯកភាពគ្នាលើចំណុចអាទិភាព វិធីសាស្ត្រ និងយន្តការអនុវត្ត ពីស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញនានា ដើម្បីរៀបចំយុទ្ធសាស្ត្រពង្រីកវិសាលភាពនៃកិច្ចគាំពារសង្គមដល់ក្រុមគោលដៅថ្មី ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ មានភាពបត់បែន និងបន្សាំទៅនឹងហានិភ័យ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ផ្សេងៗទៀតលើជីវភាពរស់នៅ និងមុខរបររបស់ប្រជាជនជនបទ។

គួររំលឹកថា គម្រោង SASI គឺជាកិច្ចសហប្រតិបត្តិការរវាង ប.ស.ស. អង្គការហ្គ្រេត (GRET) និងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) ក្នុងគោលបំណងសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ការអនុវត្តរបបសន្តិសុខសង្គម ដែលបន្សាំទៅនឹងកម្លាំងពលកម្មតាមទីជនបទ ការពង្រឹងសមត្ថភាពស្ថាប័ន ប.ស.ស. ដើម្បីឆ្ពោះទៅរកការពង្រីកការគ្របដណ្ដប់របបសន្តិសុខសង្គមសម្រាប់វិស័យកសិកម្ម នៅក្នុងការបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ និងរួមចំណែកទៅដល់ផែនទីបង្ហាញផ្លូវនៃការគ្របដណ្ដប់សុខភាពជាសកល៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អញ្ជើញជាអធិបតីបើកវេទិកាថ្នាក់ជាតិស្តីពី "គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាន"

## កម្រងរូបភាពសកម្មភាព








នាព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ មន្ត្រីជំនាញ ប.ស.ស. តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម តំណាងសហជីព តំណាងកម្មករនិយោជិត តំណាងសហភាពការងារកម្ពុជា តំណាងសមាជិក SP4ALL និងតំណាងស្ថាប័នជាតិ អន្តរជាតិ សរុបចំនួន ២៥០រូប បានចូលរួមវេទិកាថ្នាក់ជាតិស្តីពី "គាំពារសង្គមដើម្បីអន្តរកាលយុត្តិធម៌ និងសកម្មភាពបរិស្ថាន" ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អគ្គនាយករង** ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

ក្នុងឱកាសបើកវេទិកាថ្នាក់ជាតិ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអង្គការអុកស្វាម (OXFAM) ដែលបានខិតខំប្រឹងប្រែងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូក្នុងការអនុវត្តគម្រោងគាំពារសង្គមជាច្រើនកន្លងមក ដើម្បីរួមចំណែកក្នុងការពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គមនៅកម្ពុជាឱ្យកាន់តែទូលំទូលាយ និងល្អប្រសើរបន្ថែមទៀត។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានសម្តែងនូវក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា វេទិកានេះនឹងផ្តល់នូវធាតុចូល និងវិធីសាស្រ្តសំខាន់ៗ ដើម្បីជាគន្លឹះក្នុងការរៀបចំនូវយុទ្ធសាស្រ្ត និងផែនការការងារបន្ទាប់ សម្រាប់អនុវត្តការងារប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ ដែលជាការរួមចំណែកលើកកម្ពស់ និងការពង្រីករបបសន្តិសុខសង្គមទៅដល់ប្រជាជនគោលដៅឱ្យកាន់តែទូលំទូលាយ និងឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល។

ក្នុងពិធីនោះដែរ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** ក៏បានផ្តល់កិត្តិយសអញ្ជើញប្រគល់ពានរង្វាន់ជ័យលាភី នៃកម្មវិធីប្រកួតវីដេអូពានរង្វាន់ជើងឯក ប.ស.ស. ក្រោមប្រធានបទស្តីពី "របបសន្តិសុខសង្គមការពារសិទ្ធិ និងសុវត្ថិភាពរបស់អ្នក" ដល់បេក្ខជនដែលបានចូលរួមប្រកួតប្រជែងមានចំនួន៨ ក្រុមដោយក្នុងនោះមាន៣ក្រុមដែលបានជ្រើសរើសជាជ័យលាភីពីលេខ១ ដល់លេខ៣។

ជាមួយគ្នានោះដែរ **លោក ខួន ហឿន** អនុប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម នៃ ប.ស.ស. ក៏បានធ្វើបទបង្ហាញចែករំលែកចំណេះដឹងស្តីពីការអនុវត្តរបបសន្តិសុខសង្គម ជាពិសេសសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គម ដោយរួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ស្របទៅតាមការកំណត់ ដូចមានចែងក្នុងបទប្បញ្ញត្តិ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និងអញ្ជើញជាវាគ្មិនកិត្តិយស ដើម្បីឆ្លើយតបទៅនឹងសំណួរសំខាន់ៗមួយចំនួនទាក់ទងច្បាប់ស្តីពីរបបសន្តិសុខសង្គម និងស្ថានភាពរបបសន្តិសុខសង្គមនៅប្រទេសកម្ពុជា ព្រមទាំងការផ្តល់សេវាជូនសមាជិករបស់ខ្លួននាពេលបច្ចុប្បន្ន ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម៕

© រក្សាសិទ្ធិដោយបេឡាជាតិរបបសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ខេត្តប៉ៃលិន និងខេត្តបាត់ដំបង

## កម្រងរូបភាពសកម្មភាព



នៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក សាខា ប.ស.ស. ខេត្តប៉ៃលិន។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានផ្តល់អនុសាសន៍ណែនាំ ដល់ក្រុមការងារអធិការកិច្ច ត្រូវពង្រឹងបន្ថែមលើការងារចុះអធិការកិច្ច ធ្វើយ៉ាងណាត្រូវពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយនូវរាល់ចន្លោះខ្វះខាតនានា និងចាត់វិធានការភ្លាមៗចំពោះករណីល្មើសណាមួយ ដែលបានកើតឡើងក្នុងសហគ្រាស គ្រឹះស្ថាននីមួយៗ ទាក់ទងទៅនឹងការចុះបញ្ជិកា ឬបង់ភាគទានមិនបានត្រឹមត្រូវ ឬរាយការណ៍ពីស្ថានភាព នៃសហគ្រាស គ្រឹះស្ថានទាំងនោះ មិនបានត្រឹមត្រូវតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជាមួយគ្នានេះ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. ក៏បានណែនាំឱ្យសាខា ប.ស.ស. ខេត្តត្រូវរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០២៦ ឱ្យបានត្រឹមត្រូវសម្រាប់ប្រើប្រាស់លើការអនុវត្តការងាររបបសន្តិសុខសង្គម ជៀសវាងមានបាតុភាពមិនប្រក្រតីណាមួយកើតឡើង ដែលបង្ករឱ្យមានការលំបាកក្នុងការអនុវត្តការងារជូនអង្គភាពរបស់ខ្លួន។

សូមបញ្ជាក់ថា នៅថ្ងៃទី១៦ **ឯកឧត្តមអគ្គនាយករង** បានបន្តអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ខេត្តបាត់ដំបង និងបានណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ក្នុងខេត្តទាំងពីរ ត្រូវបន្តយកចិត្តទុកដាក់បំពេញតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការផ្តល់សេវាជូនសមាជិក ប.ស.ស. ដោយទំនួលខុសត្រូវខ្ពស់ និងប្រកបដោយប្រសិទ្ធភាព៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ខេត្តបន្ទាយមានជ័យ

## កម្រងរូបភាពសកម្មភាព

















នៅរសៀលថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក សាខា ប.ស.ស. ខេត្តបន្ទាយមានជ័យ ដើម្បីពង្រឹងការងារចុះអធិការកិច្ច របស់សាខា ប.ស.ស. ខេត្ត នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា។

ក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** បានណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់ ត្រូវពិនិត្យឱ្យបានលម្អិតនូវរាល់ករណីពាក់ព័ន្ធនឹងការចុះបញ្ជី និងការបង់ភាគទានរបស់និយោជកនៅក្នុងសហគ្រាសនីមួយៗ និងចាត់វិធានការភ្លាមៗ ចំពោះករណីល្មើសណាមួយ ដែលបង្កប់នូវភាពមិនប្រក្រតីក្នុងការចុះបញ្ជី និងការបង់ភាគទាន ដើម្បីធានាបាននូវការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ និងពេញលេញ ជូនដល់កម្មករនិយោជិតទាំងអស់។

**ឯកឧត្តមអគ្គនាយករង** បានបន្តលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទាំងអស់ ត្រូវខិតខំប្រឹងប្រែងបំពេញការងារលើការធ្វើទំនើបកម្មសេវា និងការប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីធានាថាសហគ្រាសថ្មីៗត្រូវបានចុះបញ្ជីយ៉ាងរហ័ស និងមានប្រសិទ្ធភាពខ្ពស់សម្រាប់ជាប្រយោជន៍ដល់សមាជិក ប.ស.ស.។

ជាមួយគ្នានេះដែរ **ឯកឧត្តមអគ្គនាយករង** បានចុះពិនិត្យតាមជាន់នីមួយៗ នៃអគារ និងបានពិនិត្យទៅលើ សម្ភារៈបរិក្ខារ ឧបករណ៍អេឡិចត្រូនិក ដែលមន្ត្រី និងបុគ្គលិកកំពុងប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីដឹងពីស្ថានភាពសម្ភារៈបរិក្ខារ ឧបករណ៍អេឡិចត្រូនិក ក្នុងកិច្ចប្រតិបត្តិការការងារប្រចាំថ្ងៃក្នុងការផ្តល់សេវាជូនសមាជិក ប.ស.ស. និងកម្មករនិយោជិតឱ្យរលូន និងមានប្រសិទ្ធភាពខ្ពស់៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ខេត្តសៀមរាប

## កម្រងរូបភាពសកម្មភាព

















នៅរសៀលថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក សាខា ប.ស.ស. ខេត្តសៀមរាប ដើម្បីពង្រឹងការងារចុះអធិការកិច្ច និងដោះស្រាយករណីល្មើសពាក់ព័ន្ធនឹងការចុះបញ្ជី ព្រមទាំងការបង់ភាគទានរបស់និយោជកតាមសហគ្រាស គ្រឹះស្ថាន ក្នុងមូលដ្ឋានរបស់ខ្លួន ធានាឱ្យបាននូវប្រព័ន្ធសន្តិសុខសង្គមមានភាពរឹងមាំ។

**ឯកឧត្តមអគ្គនាយករង** បានបន្តលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទាំងអស់ ត្រូវខិតខំប្រឹងប្រែងបន្តបំពេញការងារលើការធ្វើទំនើបកម្មសេវា និងការប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីធានាថាសហគ្រាសថ្មីៗត្រូវបានចុះបញ្ជីជាមួយ ប.ស.ស. សម្រាប់ជាប្រយោជន៍ដល់សមាជិក ប.ស.ស.។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ក៏បានអញ្ជើញចុះពិនិត្យការងារផ្ទាល់ក្នុងអគារ និងពិនិត្យតាមជាន់នីមួយៗ នូវសម្ភារបរិក្ខារ និងឧបករណ៍អេឡិចត្រូនិកប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីធានាថា សម្ភារ និងបរិក្ខារទាំងអស់ស្ថិតក្នុងស្ថានភាពប្រសើរ មានគុណភាព និងអាចប្រើប្រាស់បាន ដើម្បីគាំទ្រដល់ការអនុវត្តការងាររបស់មន្ត្រី និងបុគ្គលិកឱ្យដំណើរការរលូន ឆ្លើយតបទៅនឹងតម្រូវការការងារបច្ចុប្បន្ន៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី បន្តអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ខេត្តត្បូងឃ្មុំ

## កម្រងរូបភាពសកម្មភាព



នៅព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក សាខា ប.ស.ស. ខេត្តត្បូងឃ្មុំ ដើម្បីពង្រឹងការងារចុះអធិការកិច្ច និងដោះស្រាយករណីល្មើសពាក់ព័ន្ធនឹងការចុះបញ្ជី ព្រមទាំងការបង់ភាគទានរបស់និយោជកតាមសហគ្រាស គ្រឹះស្ថាន ក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីធានាឱ្យបាននូវប្រព័ន្ធសន្តិសុខសង្គមមានភាពរឹងមាំ។

**ឯកឧត្តមអគ្គនាយករង** បានបន្តលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទាំងអស់ ត្រូវខិតខំប្រឹងប្រែងបន្តបំពេញការងារលើការធ្វើទំនើបកម្មសេវា និងការប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីធានាថាសហគ្រាសថ្មីៗត្រូវបានចុះបញ្ជីជាមួយ ប.ស.ស. សម្រាប់ជាប្រយោជន៍ដល់សមាជិក ប.ស.ស.។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ក៏បានអញ្ជើញចុះពិនិត្យការងារផ្ទាល់ក្នុងអគារ និងពិនិត្យតាមជាន់នីមួយៗ នូវសម្ភារបរិក្ខារ និងឧបករណ៍អេឡិចត្រូនិកប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីធានាថា សម្ភារបរិក្ខារទាំងអស់ស្ថិតក្នុងស្ថានភាពប្រសើរ មានគុណភាព និងអាចប្រើប្រាស់បាន ដើម្បីគាំទ្រដល់ការអនុវត្តការងាររបស់មន្ត្រី និងបុគ្គលិកឱ្យដំណើរការរលូន ឆ្លើយតបទៅនឹងតម្រូវការការងារបច្ចុប្បន្ន៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី បន្តអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៅសាខា ប.ស.ស. ខេត្តពោធិ៍សាត់ និងខេត្តកោះកុង

## កម្រងរូបភាពសកម្មភាព



នាចុងសប្តាហ៍ ថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក សាខា ប.ស.ស. ខេត្តពោធិ៍សាត់ និងខេត្តកោះកុង និងពាំនាំការផ្តាំផ្ញើសួរសុខទុក្ខរបស់ **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល ព្រមទាំងដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលសាខាជួបប្រទះក្នុងការអនុវត្តការងារប្រចាំថ្ងៃ។

ក្នុងឱកាសជួបសំណេះសំណាល **ឯកឧត្តមអគ្គនាយករង** បានជំរុញបន្ថែមដល់ថ្នាក់ដឹកនាំសាខាខេត្តទាំង២ ក្នុងការពង្រឹងការងារចុះអធិការកិច្ចសន្តិសុខសង្គម និងដោះស្រាយរាល់ករណីល្មើសទាំងអស់ពាក់ព័ន្ធនឹងការចុះបញ្ជី ព្រមទាំងការបង់ភាគទានរបស់និយោជកតាមសហគ្រាស គ្រឹះស្ថាន នៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីធានាឱ្យបាននូវប្រព័ន្ធសន្តិសុខសង្គមមានភាពរឹងមាំ។ ជាពិសេសត្រូវសហការជាមួយតំណាងសហគ្រាស គ្រឹះស្ថាន និងអង្គភាពពាក់ព័ន្ធដើម្បីផ្សព្វផ្សាយឱ្យបានយល់ដឹងកាន់តែច្បាស់អំពីបែបបទ នីតិវិធីថ្មីៗ ដែលជាវិធីសាស្ត្រដ៏ល្អមួយអាចជំរុញការងារកាន់តែមានប្រសិទ្ធភាព។

ជាមួយគ្នានេះ **ឯកឧត្តមអគ្គនាយករង** ក៏បានផ្តល់អនុសាសន៍ណែនាំ ដល់ថ្នាក់ដឹកនាំសាខា មន្ត្រី និងបុគ្គលិក ប.ស.ស. ទាំងអស់នៃសាខាខេត្តទាំង២ ត្រូវរួមសហការគ្នាប្រកបដោយសាមគ្គីភាព និងបន្តខិតខំប្រឹងប្រែងផ្តល់សេវាជូនដល់សមាជិក ឱ្យបានកាន់តែឆាប់រហ័ស ប្រកបដោយភាពទន់ភ្លន់ ស្មោះត្រង់ យុត្តិធម៌ និងវិជ្ជាជីវៈខ្ពស់។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ក៏បានអញ្ជើញចុះពិនិត្យការងារផ្ទាល់ក្នុងអគារ និងពិនិត្យតាមជាន់នីមួយៗ នូវសម្ភារបរិក្ខារ និងឧបករណ៍អេឡិចត្រូនិកប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីធានាថា សម្ភារបរិក្ខារទាំងអស់ស្ថិតក្នុងស្ថានភាពប្រសើរ មានគុណភាព និងអាចប្រើប្រាស់បាន ក្នុងការគាំទ្រដល់ការអនុវត្តការងាររបស់មន្ត្រី និងបុគ្គលិកឱ្យដំណើរការរលូន ឆ្លើយតបទៅនឹងតម្រូវការការងារបច្ចុប្បន្ន៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ អញ្ជើញបិទសិក្ខាសាលាស្តីពី ការរៀបចំផែនការសកម្មភាព និង របាយការណ៍វឌ្ឍនភាព នៃការតាមដានត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ផ.យ.អ-ក.ស.ប) ២០២៤-២០២៨

## កម្រងរូបភាពសកម្មភាព










នារសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ នេះ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញបិទសិក្ខាសាលាស្តីពី "ការរៀបចំផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាព នៃការតាមដានត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ផ.យ.អ-ក.ស.ប) ២០២៤-២០២៨" នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

**ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានមានប្រសាសន៍ថា សិក្ខាសាលានេះមានសារៈសំខាន់បំផុតសម្រាប់ការអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ (M&E) ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ផ.យ.អ.-ក.ស.ប) ២០២៤-២០២៨ ព្រមទាំងជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៅក្នុងការកែលម្អប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ (M&E) ឱ្យកាន់តែមានលក្ខណៈស្តង់ដារ អាចវាស់វែងបាន និងមានតម្លាភាព។

**ឯកឧត្តមអគ្គនាយករង** សង្ឃឹមជឿជាក់ថា សិក្ខាកាមទាំងអស់នឹងយកចំណេះដឹង បទពិសោធន៍ និងអនុសាសន៍ល្អៗទាំងនេះ ទៅអនុវត្តឱ្យមានប្រសិទ្ធភាពនៅតាមអង្គភាពរៀងៗខ្លួន ដើម្បីធានាថា រាល់ការងារគឺពិតជាដើរស្របទៅតាមគោលដៅយុទ្ធសាស្ត្រដែលបានកំណត់៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# គណៈប្រតិភូ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញចូលរួមសិក្ខាសាលាចែករំលែកឧត្តមានុវត្តន៍ ក្រោមប្រធានបទស្តីពី វឌ្ឍនភាពរួម៖ កំណែទម្រង់បរិវត្តកម្មដើម្បីធានាអនាគតសម្រាប់ទាំងអស់គ្នា របស់សមាគមសន្តិសុខសង្គមអាស៊ាន ( ASSA ) លើកទី៤២ នៅប្រទេសព្រុយណេ

## កម្រងរូបភាពសកម្មភាព



នារសៀលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ មន្រ្តីជំនាញ ប.ស.ស. ដឹកនាំដោយ **ឯកឧត្តម ឃុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបពិភាក្សាជាមួយមន្រ្តីនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ដែលដឹកនាំដោយ**ឯកឧត្តម ឧត្តមសេនីយ៍ទោ ហេង ចំរើន** អគ្គនាយករង តំណាង **ឯកឧត្តម ឧត្តមសេនីយ៍ឯក បណ្ឌិត គុយ នេត** អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ដែលពិភាក្សាលើប្រធានបទស្តីពី "បែបបទ និងនីតិវិធីនៃ ការស្នើសុំលើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល ការបញ្ជាក់អត្តសញ្ញាណបុគ្គល ឬបញ្ជាក់អំពីភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល និងលក្ខខណ្ឌបច្ចេកទេសនៃការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល" ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំពិភាក្សាខាងលើ រៀបចំឡើងក្នុងគោលបំណងស្តាប់បទបង្ហាញពីការអនុវត្តរបស់ប្រកាសលេខ ៣៩២២ ប្រក ចុះ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីបែបបទ និងនីតិវិធីនៃ ការស្នើសុំលើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល ការបញ្ជាក់អត្តសញ្ញាណបុគ្គល ឬបញ្ជាក់អំពីភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល និងលក្ខខណ្ឌបច្ចេកទេសនៃការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ដើម្បីចូលរួមអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងស្វែងយល់ពីប្រតិបត្តិការពាក់ព័ន្ធរវាងស្ថាប័នទាំងពីរ។

ក្នុងឱកាសកិច្ចប្រជុំពិភាក្សានោះដែរ ក៏មានការធ្វើបទបង្ហាញស្តីពី ការផ្តល់សេវាផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល និងបញ្ជាក់អត្តសញ្ញាណបុគ្គល ពីមន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ អញ្ជើញជាអធិបតីបើកវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពបុគ្គលិកសម្របសម្រួលមន្ទីរពេទ្យ និងជនបង្គោលទទួល និងឆ្លើយតបរាល់បញ្ហាប្រឈមនានារបស់មូលដ្ឋានសុខាភិបាលដៃគូ"

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីបើកវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពបុគ្គលិកសម្របសម្រួលមន្ទីរពេទ្យ និងជនបង្គោលទទួល និងឆ្លើយតបរាល់បញ្ហាប្រឈមនានារបស់មូលដ្ឋានសុខាភិបាលដៃគូ" នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណជា ៨០រូប។

ក្នុងឱកាសនោះដែរ ឯកឧត្តម អគ្គនាយករង បានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះ ពិតជាសំខាន់ក្នុងការពង្រឹងសមត្ថភាពមន្ត្រី និងបុគ្គលិកជួរមុខ ក្នុងការសម្របសម្រួលការងារប្រចាំថ្ងៃ និងដោះស្រាយបញ្ហាប្រឈមនានានៅពេលសមាជិក ប.ស.ស. ចូលមកប្រើប្រាស់សេវានៅតាមមន្ទីរពេទ្យដៃគូ ប.ស.ស.។

**ឯកឧត្តមអគ្គនាយករង** សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមទាំងអស់នឹងចូលរួមយ៉ាងសកម្មក្នុងការត្រង់ត្រាប់ស្តាប់ និងសួរសំណួរឱ្យផុសផុល ទៅកាន់លោកគ្រូឧទ្ទេស ដើម្បីឱ្យគ្រូឧទ្ទេសធ្វើការបកស្រាយ និងពន្យល់លម្អិតឱ្យកាន់តែយល់ច្បាស់ ព្រមទាំងយកចំណេះជំនាញ បទពិសោធន៍នេះ ទៅបំពេញការងារប្រចាំថ្ងៃឱ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀត៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# មន្ត្រីជំនាញ ប.ស.ស. បន្តផ្សព្វផ្សាយស្តីពី "អត្ថប្រយោជន៍ នៃរបបសន្តិសុខសង្គម" ជូនដល់ថ្នាក់ដឹកនាំ និងយុវជន នៃសហភាពសហព័ន្ធយុវជនកម្ពុជា ប្រមាណជាង ៣០០រូប

## កម្រងរូបភាពសកម្មភាព










ដោយទទួលបានការអនុញ្ញាតពីសំណាក់ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៥ **លោក សុក ម្ង៉ា** ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម នៃ ប.ស.ស. បានធ្វើបទបង្ហាញស្តីពី "អត្ថប្រយោជន៍ នៃរបបសន្តិសុខសង្គម" នៅមជ្ឈមណ្ឌលម៉ានី នៃអាគារ Kampus ដោយមានអ្នកចូលរួមប្រមាណជាង ៣០០រូប។

បទបង្ហាញខាងលើធ្វើឡើងនៅក្នុងសិក្ខាសាលាស្តីពី "គោលនយោបាយជាតិគាំពារសង្គម និងរបបសន្តិសុខសង្គម" ជូនដល់ថ្នាក់ដឹកនាំ និងយុវជន នៃសហភាពសហព័ន្ធយុវជនកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមសាស្ត្រាចារ្យ សេង ផល្លី** អនុប្រធានអចិន្ត្រៃយ៍ ក្រុមប្រឹក្សាយុវជនគ្រឹះស្ថានឧត្តមសិក្សា តំណាង **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** អនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាយុវជនគ្រឹះស្ថានឧត្តមសិក្សា។

ក្នុងឱកាសនោះដែរ **លោក សុក ម្ង៉ា** បានធ្វើបទបង្ហាញចែករំលែកចំណេះដឹងស្តីពីការអនុវត្តរបបសន្តិសុខសង្គម ជាពិសេសសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមដោយរួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ស្របទៅតាមការកំណត់ ដូចមានចែងក្នុងបទប្បញ្ញត្តិ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ជូនដល់អ្នកចូលរួមក្នុងសិក្ខាសាលាទាំងអស់ ព្រមទាំងឆ្លើយតបទៅនឹងសំណួរមួយចំនួន ពីសំណាក់ថ្នាក់ដឹកនាំ និងយុវជន នៃសហភាពសហព័ន្ធយុវជនកម្ពុជា ដើម្បីឱ្យយល់កាន់តែច្បាស់ពីការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.







facebook

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
☛តើសហព័ទ្ធ (ប្ដី ឬប្រពន្ធ)
និងកូនក្នុងបន្ទុករបស់មន្ត្រីសាធារណៈ ត្រូវមានឯកសារអ្វីខ្លះ
ដើម្បីអាចស្នើសុំប័ណ្ណសមាជិក ប.ស.ស. បាន?

facebook

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពី
☛អស់លទ្ធភាពបង់ភាគទាន
តើត្រូវធ្វើដូចម្ដេច?




© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.




សាខា ប.ស.ស. នៅផ្សារទំនើបអ៊ីអន ម៉ល (AEON - MALL) ទាំង ៣ទីតាំង ក្នុងរាជធានីភ្នំពេញ បើកបម្រើការងារពីថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ២២:០០នាទីយប់ លើកលែងតែថ្ងៃបុណ្យជាតិ។ លោកអ្នកអាចទទួលបានសេវាដូចជា៖

- ✍ ធ្វើប័ណ្ណសមាជិក ប.ស.ស.
- ✍ ដាក់របាយការណ៍គ្រោះថ្នាក់ការងារ
- ✍ ស្នើសុំលិខិតព្យាបាលបន្ត
- ✍ ស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់ស្ត្រីមានផ្ទៃពោះ
- ✍ ស្នើសុំប្រាក់បំណាច់ប្រចាំថ្ងៃ និងប្រាក់បំណាច់លំហែមាតុភាព
- ✍ ស្នើសុំប្រាក់សោធន

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!




សម្រាប់សមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ទាំងអស់ អាចបង់ភាគទានមក ប.ស.ស. ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ នៃរៀងរាល់ខែ តាមរយៈធនាគារដៃគូ ប.ស.ស. ដែលរួមមាន ៖

- ✍ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA BANK PLC. )
- ✍ ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ (ABA BANK)
- ✍ ធនាគារ កាណាឌីយ៉ា ក.អ (CANADIA BANK PLC.)
- ✍ ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB Bank Cambodia)
- ✍ ធនាគារ ភ្នំពេញ ពាណិជ្ជ (PPCBank)

✍ ចំណាំ៖ សម្រាប់ការបង់ភាគទាន មក ប.ស.ស. គឺធ្វើឡើងតាមរយៈកម្មវិធីទូរសព្ទដៃធនាគារដៃគូ ខាងលើ ឬអញ្ជើញទៅកាន់ធនាគារដៃគូខាងលើដោយផ្ទាល់។

⚠ សូមប្រយ័ត្ន៖ ចំពោះការបង់ភាគទានតាមរយៈ QR CODE ឬតាមរយៈវិធីផ្សេងៗ ដែលមានឈ្មោះបុគ្គល គឺជាករណីឆបោក សូមបងប្អូនមេត្តាប្រុងប្រយ័ត្នឱ្យបានខ្ពស់ ជៀសវាងខាតបង់ថវិកាផ្ទាល់ខ្លួន។

☎ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខ ១២៨៦ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមរបស់យើង!!

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ខិត្តប័ណ្ណផ្សព្វផ្សាយ របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.

ស្វែងតាមរយៈ QR Code
ដើម្បីទាញយកខិត្តប័ណ្ណ
វិស័យឯកជន







ប.ស.ស. ហានិភ័យការងារ
ប.ស.ស. ថែទាំសុខភាព
ប.ស.ស. ប្រាក់សោធន

ស្វែងតាមរយៈ QR Code
ដើម្បីទាញយកខិត្តប័ណ្ណ
វិស័យសាធារណៈ




© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

បណ្តាញសង្គម ប.ស.ស.
Telegram | Facebook | Youtube | Tiktok | Website | Linkedin

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍

General Department of Information and Broadcasting

លេខ : ០៤៤ ព.ស-ស.ម

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥

## លិខិតអនុញ្ញាត

**យោង ៖** -ប្រកាសលេខ ១០៨ ប្រក.ព.ម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងព័ត៌មាន

-លិខិតលេខ ៤១០/២២ .ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ

-លិខិតស្នើសុំប្តូរឈ្មោះ និងទីតាំង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម។

តាមសេចក្តីដូចមានចែងក្នុងយោងខាងលើ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ជ្រាបថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន អនុញ្ញាតឱ្យព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ប្តូរឈ្មោះមកជាព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. និងមានអាសយដ្ឋានទីស្នាក់ការថ្មីស្ថិតនៅផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បន្តលិខិតលេខ ៤១០/២២-ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ក្នុងដំណើរការផ្សព្វផ្សាយ ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាស របស់ក្រសួងព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ ករណីប្រព្រឹត្តល្មើស សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ០១ (មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ត្រូវស្នើសុំបន្តសុពលភាពដើម្បីធ្វើសកម្មភាពការងារលើវិស័យព័ត៌មាន និងសោតទស្សន៍ មុនផុតកំណត់រយៈពេល ៣០ (សាមសិប) ថ្ងៃ។

**អគ្គនាយក**

**ផុស_សុវណ្ណ**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- អគ្គស្នងការនគរបាលជាតិ
- និយ័តករទូរគមនាគមន៍កម្ពុជា
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរព័ត៌មានរាជធានីភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ឯកសារ កាលប្បវត្តិ